គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

ដោយមានការគាំទ្រពី គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមន៍អាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ** កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៥៧** នាក់ (**២៩**% ជាស្ត្រី) ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុង កម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

### តម្រូវការជាអាទិភាព ទាំង ៥ ក្នុង ឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

**១. ការសាងសង់ផ្លូវលំ**

- សុំផ្លូវលំថ្មីក្រាលគ្រួសក្រហមចំនួន **៧ខ្សែ** សម្រាប់ក្នុងភូមិទាំង**៧**គឺ៖

-**ខ្សែទី១** ប្រវែង ៥៧៧ម៉ែត្រ កម្ពស់ ០,៨ម៉ែត្រ បាតក្រោម ៦ម៉ែត្រ ខ្នងលើ ៤ម៉ែត្រ ចាប់ពីភូមិសុដុលដល់វត្តសុដុល **ខ្សែទី២** ប្រវែង៣៥០០ម៉ែត្រ កម្ពស់ ០,៨ម៉ែត្រ បាតក្រោម ៨ម៉ែត្រ ខ្នងលើ ៤ម៉ែត្រ នៅភូមិស្មោញ និង**ខ្សែទី៣** ប្រវែង ២០០០ម៉ែត្រ កម្ពស់ ០,៨ម៉ែត្រ បាតក្រោម ៧ម៉ែត្រ ខ្នងលើ ៥ម៉ែត្រ នៅភូមិព្រហូត។ ផ្លូវទាំង៣ខ្សែនេះ សូមចាប់ផ្តើមសាងសង់ឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

-**ខ្សែទី៤** ប្រវែង២៥៥៤ម៉ែត្រ កម្ពស់០,៨ម៉ែត្រ បាតក្រោម៧ម៉ែត្រ ខ្នងលើ៥ម៉ែត្រ នៅភូមិព្រៃដំរី **ខ្សែទី៥** ប្រវែង១៥០០ម៉ែត្រ កម្ពស់០,៨ម៉ែត្រ បាតក្រោម៧ម៉ែត្រ ខ្នងលើ៥ម៉ែត្រ នៅភូមិផ្ញៀក **ខ្សែទី៦** ប្រវែង២០០០ម៉ែត្រ កម្ពស់០,៨ម៉ែត្រ បាតក្រោម៧ម៉ែត្រ ខ្នងលើ៥ម៉ែត្រ នៅភូមិត្រពាំងផ្លុង និង**ខ្សែទី៧** ប្រវែង២០០០ម៉ែត្រ កម្ពស់០,៨ម៉ែត្រ បាតក្រោម៨ម៉ែត្រ ខ្នងលើ៤ម៉ែត្រ នៅភូមិក្រញូង។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១៣ និងបញ្ចប់នៅឆ្នាំ២០១៤។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

| |
|---|
| **២. ការជីកប្រឡាយទឹក និងដាក់លូ**<br>• សុំប្រឡាយទឹកថ្មីចំនួន**០៦កន្លែងគឺៈ ប្រឡាយទឹកទី១** មានប្រវែង២០០០ម៉ែត្រ ជម្រៅ០,៥ម៉ែត្រ បាត០,៥ម៉ែត្រ មាត់លើ០,៥ម៉ែត្រ ចាប់ពីបឹងរលំដល់ចំនុចខាងលិចបឹងភូមិផ្អៀក **ប្រឡាយទឹកទី២** ប្រវែង២០០០ម៉ែត្រ ជម្រៅ០,៥ម៉ែត្រ បាត០,៥ម៉ែត្រ មាត់លើ០,៥ម៉ែត្រ នៅភូមិព្រៃដំរី **ប្រឡាយទឹកទី៣** ប្រវែង២០០០ម៉ែត្រ ជម្រៅ០,៥ម៉ែត្រ បាត០,៥ម៉ែត្រ មាត់លើ០,៥ម៉ែត្រ មានទ្វាបិទបើក៣ម៉ែត្រ មានលូបង្ហូរទឹកចំនួន៥កង់ និងមានអាងស្តុកទឹកចំនួន២កន្លែង នៅភូមិត្រពាំងផ្លុង ត្រង់ចំនុចត្រពាំងរមាស និងត្រពាំងធំ **ប្រឡាយទឹកទី៤** ប្រវែង២០០០ម៉ែត្រ ជម្រៅ៤ម៉ែត្រ បាត៤ម៉ែត្រ មាត់លើ៨ម៉ែត្រ ចាប់ពីស្ទឹងមកដល់ភូមិក្រញូង **ប្រឡាយទឹកទី៥** មានប្រវែង៣៥០០ម៉ែត្រ ជម្រៅ០,៥ម៉ែត្រ បាត០,៥ម៉ែត្រ មាត់លើ០,៥ម៉ែត្រ ចាប់ពីអំពកតូចដល់កែងសំណង់ទី៣ ភូមិស្នោញ **ប្រឡាយទឹកទី៦** ប្រវែង២០០០ម៉ែត្រ ជម្រៅ០,៥ម៉ែត្រ បាត០,៥ម៉ែត្រ មាត់លើ០,៥ម៉ែត្រ ចាប់ពីភូមិម្នាងដល់អំពកតូច ដោយធ្វើតាមស្តង់ដាប្រឡាយចាស់។ សូមចាប់ផ្តើមនៅឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |
| **៣. ការធ្វើអណ្តូងទឹក**<br>• សុំអណ្តូងទឹកសរុបចំនួន៣៧៨អណ្តូង ដោយដាក់លូជម្រៅ៧ម៉ែត្រ សម្រាប់ប្រជាពលរដ្ឋ៨ភូមិ ដែលក្នុងនោះមានភូមិផ្អៀកចំនួន**១០អណ្តូង** ភូមិត្រពាំងផ្លុងចំនួន**១០អណ្តូង** ភូមិព្រៃដំរីចំនួន**៦អណ្តូង** ភូមិស្នោញចំនួន**៩៥អណ្តូង** ភូមិព្រហូតចំនួន**១៥០អណ្តូង** ភូមិក្រញូងចំនួន**៥០អណ្តូង** ភូមិសុជុលនិងភូមិស្រមរចំនួន**៥៧អណ្តូង**។ សូមចាប់ផ្តើមធ្វើនៅឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |
| **៤. ការធ្វើបង្គន់អនាម័យ**<br>• សុំបង្គន់អនាម័យសរុបចំនួន ៦៩៣បង្គន់ ដោយសាងសង់តាមស្តង់ដាបង្គន់នៅសាលាឃុំជាន់ញើម សម្រាប់ភូមិ៧ ដែលក្នុងនោះរួមមាន***ភូមិស្នោញ***ចំនួន១២០បង្គន់ ***ភូមិព្រហូត***ចំនួន២០០បង្គន់ ***ភូមិក្រញូង***ចំនួន៨០បង្គន់ ***ភូមិផ្អៀក***ចំនួន៣០បង្គន់ ***ភូមិត្រពាំងផ្លុង***ចំនួន២៥បង្គន់ ***ភូមិសុជុល***និង***ភូមិស្រមរ***ចំនួន២៧០បង្គន់។ សូមចាប់ផ្តើមធ្វើនៅឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |
| **៥. ការសាងសង់មណ្ឌលសុខភាព**<br>• សុំសាងសង់មណ្ឌលសុខភាព១ខ្នង តាមស្តង់ដារបស់មណ្ឌលសុខភាពឃុំដូង ដែលមាន៤បន្ទប់ មានគ្រូពេទ្យ៥នាក់ មាននារី៣នាក់ និងប្រុស២នាក់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **យឹង តឹប** តំណាងគណបក្សប្រជាជនកម្ពុជា ជាប្រធានក្រុមប្រឹក្សាឃុំ បានមានប្រសាសន៍ថា «ឃុំបានដាក់ចូលក្នុងកម្មវិធីវិនិយោគរបស់ឃុំរួចហើយ។ លោកបានបន្តថាលោកបានប្តេជ្ញាចិត្ត និងសន្យាថាបើគណបក្សលោកជាប់ឆ្នោតនៅអាណត្តិក្រោយ លោកនឹងខិតខំស្វែងរកស្ថាប័ននានាមកអភិវឌ្ឍន៍ឃុំឲ្យបានរីកចំរើនតទៅមុខទៀត»។

លោក **មាស យៅ** ជាជំទប់ទី១ តំណាងគណបក្សហ៊្វុនស៊ិនប៉ិច បានមានប្រសាសន៍ថា «បើលោកជាប់ឆ្នោត លោកនឹងខិតខំសហការជាមួយក្រុមប្រឹក្សាឃុំ ហើយនិងស្វែងរកជំនួយពីអង្គការនានាដើម្បីជួយដោះស្រាយបញ្ហាជូនបងប្អូនប្រជាពលរដ្ឋ»។

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។
២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។
៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូច មឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៤៧១ ៣២៦**

២-កញ្ញា **គោត ស្រីពេជ្រ** (អ្នកស្ម័គ្រចិត្តផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០៨៩ ៨១៨ ១៧៦**

---

[1] No 079